# របាំច្រូតស្រូវ

សិល្បៈខ្មែរនានា ទាំងរូបីនិងអរូបី ឆ្លុះបញ្ចាំងពីជីវិត បទពិសោធន៍ ស្ថានភាព និងជីវភាពរស់នៅក្នុងសង្គមខ្មែរ។ ដោយសិល្បៈ មានប្រភពនិងកំណើតកើតចេញពីទំនៀមទម្លាប់ ប្រពៃណី និងសាសនា ក៏ដូចជាជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរអ្នកស្រែចម្ការ របាំប្រពៃណីខ្មែរ ក៏បង្កប់នូវអត្ថន័យខ្លឹមសារជាច្រើនដែលពាក់ព័ន្ធនឹង ជាពិសេសកសិកម្ម។ «របាំច្រូតស្រូវ» យកលំនាំតាមជីវិតនិងសកម្មភាពកសិកម្ម ជាពិសេសក្នុងរដូវច្រូតកាត់ដែលសិល្បករសិល្បការិនីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ផ្ដិតយកជាខ្លឹមសារនិងគំនិត ហើយបានច្នៃប្រឌិតបង្កើតជារបាំនេះឡើង។

«របាំច្រូតស្រូវ» មានចលនាទន់ភ្លន់ ឆ្លុះបញ្ចាំងអំពីសកម្មភាពកសិកម្ម ដូចជាស្ទូងស្រូវនិងច្រូតស្រូវ ជាដើម។ ខ្មែរយើងប្រើឧបករណ៍មួយចំនួនដើម្បីនឹងច្រូតកាត់ប្រមូលផលពីស្រែស្រូវ ដូចជា «កណ្ដៀវ» ដែលមានច្រើនប្រភេទ មានកណ្ដៀវខ្វាង កណ្ដៀវស្នាប កណ្ដៀវត្រកងឬកណ្ដៀវលំពាស់ និងកណ្ដៀវទំពក់ (សូមមើលរូបភាព)។

ចម្រៀងនិងតន្ត្រីកំដររបាំច្រូតស្រូវ មានបីបទ៖ ១) បទខ្មែរក្រងផ្កា ២) បទខ្មែរច្រូតស្រូវ និង៣) បទឡាំលាវ។

## បទខ្មែរច្រូតស្រូវ

១. បើនាងច្រូតស្រូវ ច្រូតនឹងកណ្ដៀវ
ស្រីតូចពាងពាវ កណ្ដៀវបងឲ្យ។
២. បើស្រីនាងច្រូត ស្រីកុំបណ្ដោយ
មើលមុខមើលក្រោយ ប្រយ័ត្នមុតដៃ។

## បទឡាំលាវ

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

១. យើងកសិករ មានចិត្តស្មោះសរ

នាំគ្នាធ្វើការ សម្បូណ៌សប្បាយ

សម្បូណ៌ផលា កសិករខេមរា

ផុតទុក្ខភ័យ។

២. យើងកសិករ មានចិត្តស្មោះសរ

នាំគ្នារាំលេង កម្សាន្តសប្បាយ

លើវាលធំធេង ប្រុសស្រីចាស់ក្មេង

សូមអញ្ជើញរាំ។

ចម្រៀងទាំងពីរបទខាងលើនេះ លាតត្រដាងនិងបង្កប់នូវអត្ថន័យខ្លឹមសារ ដក់ជាប់នៅក្នុងបេះដូងរបស់បុរសខ្មែរ ដែលយកចិត្តទុកដាក់ គិត និងស្រឡាញ់នារីរបស់ខ្លួនជាប្រពន្ធក៏ដូចជាសង្សារ ដូចដែលចម្រៀងដំពីពោះ រៀបរាប់អំពីការច្រូតកាត់ដោយប្រើឧបករណ៍ជាតិពន្ធុ កណ្ដៀវ ព្រមទាំងការរំឭកដល់នាងថា ប្រយ័ត្នមុតដៃ។ ម្យ៉ាងទៀត ពាក្យពេចន៍នៅក្នុងចម្រៀង ក៏ផ្ដល់ជារូបភាពដល់ទស្សនិកជនឱ្យស្រមៃឃើញការនាំគ្នាធ្វើការ ដើម្បីភោគផលសម្បូណ៌ផលា និងដើម្បីឲ្យជីវភាពគ្រួសារនិងសង្គមផុតទុក្ខព្រួយ។ នៅទីបញ្ចប់របាំច្រូតស្រូវបង្ហាញអំពីការសប្បាយរីករាយ បន្ទាប់ពីការប្រមូលផលសម្បូណ៌ហូរហៀរ។ ខ្មែរយើងខ្វះនាសម័យឥឡូវ មិនដែលបានឃើញនិងស្គាល់ឧបករណ៍កសិកម្ម «កណ្ដៀវ» នេះទេ។ ដោយការវិវត្តនិងការអភិវឌ្ឍឧបករណ៍និងរបស់របរប្រើប្រាស់ទាន់សម័យឧបករណ៍បុរាណដូចជាកណ្ដៀវខ្មែរ ក៏មានភាពរេស្តចនិងចុះឱនថយ ព្រមទាំងប្រឈមនឹងការបាត់បង់ទៅថ្ងៃអនាគតទៀតផង៕

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង






អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



## ឯកសារពិគ្រោះ

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang. (1998). *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង